អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃ ព្រហស្បតិ៍ ទី ២២ ខែ កញ្ញា ឆ្នាំ ២០១១

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២

នៅថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានសម្រេចបំបែកសំណុំរឿង ០០២ ជាផ្នែកតូចៗ ដើម្បីជំនុំជម្រះ និងវិនិច្ឆ័យសេចក្តីដាច់ដោយឡែកពីគ្នា។ អង្គជំនុំជម្រះសូមប្រកាសផងដែរថា កម្មវត្ថុនៃការជំនុំជម្រះនៅដំណាក់កាលដំបូងនេះ ជាមូលដ្ឋានគឺពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ (ដំណាក់កាលទីមួយ និងដំណាក់កាលទីពីរ) និង បទចោទដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

ការបំបែកកិច្ចដំណើរការនីតិវិធី ជាផ្នែកៗនេះ គឺមានអត្ថប្រយោជន៍ធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងមិនចំណាយពេលវេលាច្រើនក្នុងការបញ្ចប់ការជំនុំជម្រះនីមួយៗ។ នៅពេលចប់ការជំនុំជម្រះនីមួយៗ អង្គជំនុំជម្រះនឹងចេញសាលក្រម ដោយផ្តន្ទាទោសសមស្រប ក្នុងករណីរកឃើញថា មានពិរុទ្ធភាព។

ដីកាសម្រេចដែលចេញនៅថ្ងៃនេះ គឺអនុវត្តតាមវិធានថ្មីមួយដែលត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គ អ.វ.ត.ក កាលពីក្នុងខែ កុម្ភៈ ឆ្នាំ ២០១១ ដែលផ្តល់លទ្ធភាពឲ្យអង្គជំនុំជម្រះដំណើរការនីតិវិធីជំនុំជម្រះលើផ្នែកតូចៗនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប្រសិនបើខ្លួនយល់ឃើញថា ដើម្បីជាប្រយោជន៍នៃយុត្តិធម៌។ ក្រោយពីបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះនឹងមិនបោះបង់ចោលផ្នែកដែលនៅសេសសល់ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ ផ្នែកដែលនៅសេសសល់ទាំងអស់នោះគឺជាកម្មវត្ថុនៃការជំនុំជម្រះនៅដំណាក់កាលបន្ទាប់ទៀត។ វិធាននេះក៏អនុញ្ញាតឲ្យអង្គជំនុំជម្រះបំបែកការជំនុំជម្រះពាក់ព័ន្ធនឹងជនជាប់ចោទម្នាក់ ឬ ច្រើននាក់ផងដែរ។ ថ្វីត្បិត នៅពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះកំពុងពិចារណាទៅលើការជំទាស់នានាអំពីបញ្ហាកាយសម្បទា និងបញ្ហាស្មារតី របស់ជនជាប់ចោទពីររូប ក្នុងការចូលរួមសវនាការក្តី ក៏អង្គជំនុំជម្រះមិនទាន់បានចេញសេចក្តីសម្រេចណាមួយលើបញ្ហានេះនៅឡើយទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមបញ្ជាក់ថា ដីកាដែលចេញនៅថ្ងៃនេះគឺពាក់ព័ន្ធត្រឹមតែទៅនឹងលំដាប់លំដោយនៃសំណុំរឿង ០០២ និងវិសាលភាពនៃអង្គហេតុ និងអង្គច្បាប់សម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូងនេះតែប៉ុណ្ណោះ។

នៅក្នុងការសម្រេចចាប់ផ្តើមបើកសវនាការដំណាក់កាលដំបូងលើបញ្ហាស្តីពីការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គជំនុំជម្រះនឹងខិតខំធ្វើយ៉ាងណាឲ្យការជំនុំជម្រះនាពេលខាងមុខបំពេញតាមកាលប្បវត្តិ និងលំដាប់លំដោយត្រឹមត្រូវនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ និង

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

ចាប់ផ្ដើមពីរយៈកាលដើមដំបូងបំផុតដូចមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ចន្លោះឆ្នាំ ១៩៧៥-១៩៧៦) ហើយធានាថា បញ្ហាទាំងឡាយដែលលើកយកមកពិនិត្យដេញដោលនៅក្នុងសវនាការដំណាក់កាលដំបូងនេះនឹងផ្ដល់ជាមូលដ្ឋានសម្រាប់ការពិចារណាអំពីតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងអស់ ក៏ដូចជាដើម្បីផ្ដល់ជាមូលដ្ឋានគ្រឹះសម្រាប់ការជំនុំជម្រះលើបទចោទដែលនៅសេសសល់នៅដំណាក់កាលក្រោយៗទៀត។ ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងអំឡុងពេលខាងលើក៏បានប៉ះពាល់មកលើប្រជាជនកម្ពុជាទូទាំងប្រទេស រួមទាំងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនធំនៅក្នុងសំណុំរឿង ០០២ ផងដែរ។

នៅក្នុងបរិបទពិសេសនៃអ.វ.ត.ក ការបំបែកដំណើរការនីតិវិធីនឹងជួយដល់អង្គជំនុំជម្រះឲ្យការពារបាននូវផលប្រយោជន៍របស់ជនរងគ្រោះក្នុងការទទួលបាននូវយុត្តិធម៌ប្រកបដោយអត្ថន័យ និងទាន់ពេលវេលា ក៏ដូចជាដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទទាំងអស់ក្នុងសំណុំរឿង០០២ ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័សផងដែរ។ បទពិសោធន៍របស់តុលាការអន្តរជាតិនានា កន្លងមក បានបង្ហាញថា ប្រសិនបើមិនធ្វើការបំបែកនីតិវិធីនៅក្នុងរឿងក្ដីដែលមានលក្ខណៈស្មុគស្មាញ ស្រដៀងគ្នានឹងសំណុំរឿង ០០២ នេះទេ តុលាការទាំងនោះ ភាគច្រើន ត្រូវការពេលវេលារហូតទៅដល់១០ ឆ្នាំ ទើបចេញសាលក្រមបាន។

នៅពេលឆាប់ៗខាងមុខ អង្គជំនុំជម្រះសាលាដំបូងនឹងផ្ដល់ជូនបន្ថែមនូវផ្នែកលម្អិតនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះពាក់ព័ន្ធនឹងការជំនុំជម្រះដំណាក់កាលដំបូងនេះ។ អង្គជំនុំជម្រះនឹងជូនព័ត៌មានទាក់ទងនឹងការជំនុំជម្រះដំណាក់កាលបន្ទាប់ក្នុងសំណុំរឿង ០០២ លើផ្នែកដែលនៅសេសសល់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ដែលក្នុងនោះមានផ្នែកស្ដីពីសហករណ៍, ការដ្ឋាន, មន្ទីរសន្តិសុខ, កន្លែងសម្លាប់មនុស្ស និងឧក្រិដ្ឋកម្មផ្សេងៗទៀត រួមទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ផង) នៅពេលក្រោយ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥(0)១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥ (0)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្ដីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៣ ២៨៣
សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh